# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមិថុនា ឆ្នាំ២០២២

នៅក្នុងខែមិថុនា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១** សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ

-បានអនុញ្ញាតជូនលោកជំទាវ **Dalila Yasmin AMRI SUED** ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋរវ៉ាន់ដា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-បានអនុញ្ញាតឱ្យឯកឧត្តមបណ្ឌិត **មហាំម៉ាត់ អាប់ឌុលការីមអាល់អ៊ីសា** (MOHAMMA ABDULKARIM AALISSA) អគ្គលេខាធិការសម្ព័ន្ធពិភពឥស្លាម (MWL/RABITA) ប្រធានសមាគមបញ្ញវន្តឥស្លាម ចូលជួបសម្តែងការគួរសម និងសវនាការ។

ខ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធអគារទីចាត់ការថ្មីចំនួន១ខ្នង កម្ពស់២ជាន់ មាន១៥បន្ទប់ ដែលជាអំណោយរបស់លោកឧកញ៉ា **លៀង ផន** និងលោកជំទាវ **ឈឹម ណារី** ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅវិមានព្រឹទ្ធសភា។

គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានចុះហត្ថលេខា និងផ្តល់យោបល់លើឯកសារផ្សេងៗចំនួន២៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣០ច្បាប់។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា**

**ក-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារទីចាត់ការថ្មី ចំនួន១ខ្នង កម្ពស់២ជាន់ មាន១៥បន្ទប់ ដែលជាអំណោយរបស់លោកឧកញ៉ា **លៀង ផន** និងលោកជំទាវ **ឈឹម ណារី** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅវិមានព្រឹទ្ធសភា។

**ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤០ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ខេព ឯន អនុប្រធានទី២ ព្រឹទ្ធសភា**

**ក-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម ស្ថិតនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញពិសារអាហារពេលល្ងាចជាមួយតំណាងក្រុមហ៊ុនចិនប្រចាំការសាងសង់ផ្លូវជាតិលេខ១០ ស្ថិតនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-បានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅវិមានព្រឹទ្ធសភា។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

## ២.១ មុខងារនីតិកម្ម

-បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើគម្រោងថវិកាឆ្នាំ២០២៣របស់ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

## ២.២ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីសកម្មភាពការងារ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ពុទ្ធសាសនបណ្ឌិត្យ នៅរាជធានីភ្នំពេញ។

## ២.៣ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន៩ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៥ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៧ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៥ករណី ធ្វើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន២ករណី

-បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការបែងចែកការងារ និងស្រាវជ្រាវឯកសារពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីត្រៀមចុះបំពេញបេសកកម្មទៅខេត្តព្រះសីហនុ នៅសាលប្រជុំគណៈកម្មការទី៧

-បានអញ្ជើញចូលរួមកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ស្តីពីការត្រៀមរៀបចំពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ ក្នុងក្រុងក្រចេះ ខេត្តក្រចេះ

-បានអញ្ជើញចូលរួមប្រជុំដកពិសោធន៍ការងារស្រុកជើងព្រៃ នៅខេត្តកំពង់ចាម

-បានអញ្ជើញប្រជុំជាមួយលោកជំទាវ **ខាំ សុភាព** អភិបាលរងខេត្តក្រចេះ ដើម្បីរៀបចំពិធីអបអរសាទរខួបលើកទី៧៣ នៃទិវាកុមារអន្តរជាតិ ១ មិថុនា និងពិនិត្យពិភាក្សាលើបញ្ហាផ្សេងៗ នៅសង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ

-បានអញ្ជើញចូលរួមប្រជុំគណៈកម្មការ ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ ដើម្បីពិនិត្យ និងពិភាក្សាលើឯកសារត្រៀមដើម្បីផ្តល់ កិច្ចសម្ភាសន៍ជូនសារព័ត៌មានវីអូឌី (VOD) នៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយ ឯករាជ្យ (ស៊ីស៊ីអាយអ៊ឹម) ដែលគ្រោងធ្វើឡើងនាពេលខាងមុខ នៅសាលប្រជុំគណៈកម្មការទី៨ ព្រឹទ្ធសភា

-បានធ្វើបទបង្ហាញស្តីពី " រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា " ជូនសាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដា ចំនួន៩៨នាក់ នៅសាលសិក្ខាសាលាខាងជើងព្រឹទ្ធសភា

-បានអញ្ជើញជាកិត្តិយសក្នុងពិធីប្រគល់ និងទទួលអំណោយថ្នាំពេទ្យ និងគ្រឿងសម្ភារបរិក្ខារពេទ្យ ជាអំណោយរបស់អង្គការចែករំលែកសង្គ្រោះជីវិតសកល (Global Life Sharing) ក្រោមអធិបតីភាពឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម **Park Heung-Kyeong** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានបែងចែកជូនដល់មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត, មន្ទីរពេទ្យគន្ធបុប្ផា រាជធានីភ្នំពេញ ,ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨, ក្រុមសមាជិកាព្រឹទ្ធសភា, ខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីខួបលើកទី៤៥ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត (២០ មិថុនា ២០២២) និងសម្ពោធសមិទ្ធផលនានា នៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះX១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ផាម មិញ ជិញ** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

-បានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺ Covid-19 ដូសជំរុញ (ដូសទី៥) នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

-បានអញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន៣៨លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ និង

សម្តេចសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេស អំពាវនាវដល់ប្រជាពលរដ្ឋឱ្យទៅចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឱ្យបានគ្រប់គ្នា នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកែប ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តស្ទឹងត្រែង ចំនួន១៨៣លើក ។

## ២.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា តាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់ រួមមាន៖ កិច្ចប្រជុំប្រចាំឆ្នាំរបស់ AIPACODD លើកទី៥ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្តីពីគ្រឿងញៀន, កិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមអ្នកនយោបាយអាយប៉ាលើកទី១៣ ក្រោមប្រធានបទ " ការអនុវត្តលើសេចក្តីសម្រេចនៃមហាសន្និបាតអាយប៉ាលើកទី៤២ និងកិច្ចសហប្រតិបត្តិការលើសេដ្ឋកិច្ចឌីជីថលក្នុងអាស៊ានក្រោយវិបត្តិកូវីដ-១៩ ", កិច្ចប្រជុំក្រុមការងារ APF ដើម្បីត្រៀមចូលរួមមហាសន្និបាតលើកទី៤៧ នៃសភាប្រើភាសាបារាំង នៅទីក្រុងហ្គីហ្គាលី ប្រទេសរវ៉ាន់ដា, កិច្ចប្រជុំគណៈកម្មការកិច្ចការសភា APF ក្រោមអធិបតីភាពឯកឧត្តម Joël Godin ប្រធានគណៈកម្មការកិច្ចការសភា APF នៅសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល ប្រទេសបែលហ្ស៊ិក, និងកិច្ចប្រជុំត្រៀមរៀបចំមហាសន្និបាតអាយប៉ា លើកទី៤៣ ដែលសភាកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

ថ្ងៃ ច័ន្ទ ៦កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០២២

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

**កិត្តិសង្គហបណ្ឌិត ទេព ងន**

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ